មជ្ឈមណ្ឌលឯកសារកម្ពុជា

# ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានក្រើនរំឭកឲ្យផ្តោតលើសក្ខីកម្ម អំពីអង្គហេតុដែលជាប់ពាក់ព័ន្ធ

*ដោយលោក ម៉ៃខល សាលីបា*

*ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខែន សុខស្រីនិត និង វ៉ាន់ថាន់ ពៅដារ៉ា*

អង្គសវនាការបានចាប់ផ្តើមបន្តដំណើរការ ដោយទទួលស្គាល់អំពីការវិវត្តន៍ទៅមុខដែលខ្លួនបានសម្រេចកាលពីសប្តាហ៍កន្លងទៅនៅក្នុងការជំនុំជម្រះសេចក្តីប្រឆាំងនឹង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ។ ស្របតាមនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ថ្ងៃនេះខ្លួនមានគម្រោងនឹងស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាលើកចុងក្រោយ បន្ទាប់មកគឺសក្ខីកម្មរបស់សាក្សីជំនាញនៅថ្ងៃស្អែកលើបញ្ហាទាក់ទិននឹងបណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ទាប់មកទៀត អង្គជំនុំជម្រះសាលាដំបូងនឹងចំណាយពេលប្រមាណពីរថ្ងៃ ដើម្បីស្តាប់ការសួរដេញដោលរបស់មេធាវីការពារក្តីលើការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូង នឹងទទួលយកសក្ខីកម្មដែលទាក់ទិននឹងអត្តចរិករបស់ជនជាប់ចោទ មុននឹងកំណត់ថ្ងៃសម្រាប់សវនាការសួរដេញដោលចុងក្រោយ ។

ដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះ ពុំបានដំណើរការទៅមុខលឿនដូចដែលបានរំពឹងទុកនោះទេ ដោយសារតែមួយផ្នែកធំគឺដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយងាកចេញពីអង្គហេតុដែលជាប់ពាក់ព័ន្ធ ក្នុងកំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ខ្លួន ។ យោងតាមវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្គាប់ឲ្យផ្តល់សក្ខីកម្មលើព្យសនកម្មផ្នែករូបរាងកាយ សម្ភារៈ និងសតិបញ្ញា ដែលទទួលរងផ្ទាល់ដោយផលវិបាកនៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ ។ បញ្ហានេះគឺជាប់ពាក់ព័ន្ធ នឹងការបង្កើតចំណងគ្រួសាររវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅគុកទួលស្លែង (មន្ទីរស-២១) ។ ទាំងចៅក្រម ទាំងមេធាវីការពារក្តីសុទ្ធតែបានយល់ដឹងពីដើមហេតុដែលថា គោលបំណងចម្បងនៃការចូលរួម របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីនេះ គឺដើម្បីជួយឲ្យខ្លួនអាចដោះស្រាយនូវវិនាសកម្មទាំងឡាយដែលខ្លួនបានទទួលរងគ្រោះ ។ អាស្រ័យហេតុនេះ ចៅក្រមមិនត្រូវរារាំងដោយបង្អាក់ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីកាលពីសប្តាហ៍មុននោះទេ បើទោះបីជាការផ្តល់សក្ខីកម្មនោះបានស៊ីពេលលើសពីថវៈវេលា

កំណត់ក៏ដោយ ។ ខណៈពេលដែលដើមបណ្តឹងរដ្ឋប្បវេណីកាលពីសប្តាហ៍មុនបាននិយាយរាកចេញពីអង្គហេតុដែលជាប់ពាក់ព័ន្ធខ្លះៗ ថ្ងៃនេះដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើដូច្នេះម្តងទៀត ដោយនិយាយលើសពីថេរៈវេលាដែលត្រូវបានពន្យាឲ្យទៅទៀត ។ ការធ្វើបែបនេះ បានធ្វើឲ្យចៅក្រមប្រធានជំនុំជម្រះសំណូមពរជាច្រើនដងថា ដើមបណ្តឹងរដ្ឋប្បវេណីគួរផ្តោតលើសក្ខីកម្មរបស់ខ្លួនឡើងវិញម្តងទៀត ហើយបញ្ហានេះបានធ្វើឲ្យដំណើរការរបស់អង្គសវនាការទាំងមូលនៅក្នុងថ្ងៃនេះមានភាពយឺតយ៉ាវ ។

អង្គជំនុំជម្រះសាលាដំបូងក៏បានជម្រាបជូនសាធារណៈជនបន្ថែមទៀតថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ីលកេ ស្ទូហ្ស៊ីនស្គី (Silke Studzinsky) បានសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ នៅចុងសប្តាហ៍នេះ ហើយទំនងជាអវត្តមានពីបន្ទប់សវនាការសម្រាប់រយៈពេលយូរ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតនឹងសហការ និងសម្របសម្រួលគ្នាឲ្យបានល្អតាមដែលអាចធ្វើបាន ដើម្បីឲ្យសវនាការជំនុំជម្រះសេចក្តីនេះបន្តដំណើរការបានឆាប់រហ័ស ។

## **សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបន្ត**

នៅព្រឹកនេះ អ្នកស្រី ជុំ នៅ បានបន្តផ្តល់សក្ខីកម្មតទៅទៀត ដោយរៀបរាប់ពីរយៈពេលចុងក្រោយនៃការឃុំខ្លួនរបស់អ្នកស្រីនៅព្រៃស (មន្ទីរស-២៤) ។ ក្រោយពីកូនរបស់អ្នកស្រីស្លាប់ទៅ អ្នកស្រីត្រូវបានបង្ខំឲ្យធ្វើការងារពេញម៉ោងនៅតាមវាលស្រែ រហូតទល់នឹងកងទ័ពវៀតណាមបានវាយកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ក្នុងកំឡុងពេលនៃការរត់គេចខ្លួន អ្នកស្រី ជុំ នៅ បានជួបឌុចនៅក្នុងព្រៃដែលជាកន្លែងសម្រាប់ក្រុមភៀសខ្លួនបានពួន ។ ខណៈពេលដែលអ្នកស្រី ជុំ នៅ សសៀរៗទៅក្បែរ ឌុច បានដកកាំភ្លើងខ្លីចេញពីស្រោម ហើយភ្ជួងចំគុំត្រចៀករបស់អ្នកស្រី ។ (ក្រោយមក ឌុច បានបដិសេធចំពោះភាពត្រឹមត្រូវនៃហេតុការណ៍នេះ) ។ ឌុច បានប្រាប់អ្នកស្រីថា គាត់ពិតជាវនការភ្ញាក់ផ្អើលដែលថា អ្នកស្រីបានជាប់ឃុំនៅមន្ទីរស-២៤ រយៈពេលពីរឆ្នាំហើយនៅតែមានសុខភាពមាំទាំទៀត ។ ការជួបគ្នារវាង អ្នកស្រី ជុំ នៅ និង ឌុច ត្រូវបានកាត់ផ្តាច់ដោយការបាញ់ពីចម្ងាយដែលជម្រុញឲ្យក្រុមភៀសខ្លួននេះបន្តដំណើរភៀសខ្លួនតទៅមុខទៀត ។

ចៅក្រម ហ្សង់ម៉ាក់ ឡាវែញ បានសួរបន្ថែមទៀតពីការជួបគ្នារបស់អ្នកស្រី ជុំ នៅ និង ឌុច ។ លោកចៅក្រមបានកត់សម្គាល់ថា បើទោះបីជាការជួបគ្នានេះបានកើតឡើងក្រោយព្រឹត្តិការណ៍ ដែល

តុលាការមានដែនសមត្ថកិច្ចក៏ដោយ ការរៀបរាប់របស់អ្នកស្រីនៅតែជាប់ពាក់ព័ន្ធនឹងបញ្ហាអត្តចរិករបស់ ឌុច ជាដដែល ។ អ្នកស្រីបានពន្យល់ថា អ្នកស្រីបានជួប ឌុច ពីរដងមុននឹងការជួបគ្នានៅក្នុងព្រៃនោះ ។ ក្នុងអំឡុងពេលទាំងប៉ុន្មានថ្ងៃនោះ ឌុច បានក្រើនរំឭកគាត់ឲ្យមានភាពប្រុងប្រយ័ត្ន ពីព្រោះថា នឹងមានប្រធានចុះមកពិនិត្យការងារ ។ អ្នកស្រីបានឃើញ ឌុច ដើរតែម្នាក់ឯងដោយគ្មានអ្នកតាមការពារទេ ហើយបើយោងតាមសម្ដីរបស់អ្នកស្រី ឌុច មើលទៅហាក់ដូចជាមានទឹកមុខរីករាយ និងមិនព្រួយបារម្ភអ្វីទាំងអស់ ។ វាមិនហាក់បីដូចជាថា ឌុច មិនបានព្រួយបារម្ភពីទុក្ខវេទនា និងភាពឈឺចាប់នៅមន្ទីរស-២៤ទាល់តែសោះ ។ ឌុច ក៏បានបដិសេធចំពោះសក្ខីកម្មរបស់អ្នកស្រីត្រង់ផ្នែកនេះ ដោយបញ្ជាក់ថា គាត់មិនដែលមានវត្តមាននៅមន្ទីរស-២៤ ដែលនឹងធ្វើឲ្យអ្នកទោសអាចមើលឃើញគាត់ឡើយ ។

អង្គសវនាការនៅពេលរសៀលចាប់ផ្ដើមដំណើរការជាបន្តដោយស្ដាប់សក្ខីកម្មរបស់អ្នកស្រី ឈិន ណាវី ដែលប្ដីរបស់គាត់ត្រូវបានសម្លាប់នៅមន្ទីរស-២១ ។ អ្នកស្រី ឈិន ណាវី បានបែកពីប្ដីរបស់អ្នកស្រីខណៈពេលដែលមានការជម្លៀសចេញទីក្រុងភ្នំពេញកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប្ដីរបស់អ្នកស្រីនៅខាងក្រោយ ប៉ុន្ដែមុននឹងអ្នកទាំងពីរបែកគ្នា ប្ដីរបស់អ្នកស្រីបានឲ្យអ្នកស្រីសន្យាថា នឹងថែរក្សាខ្លួន និងកូនៗឲ្យបានល្អ ។ អ្នកស្រីបានរៀបរាប់ពីអារម្មណ៍អស់សង្ឃឹមដោយគិតថា ប្ដីរបស់អ្នកស្រីនឹងមិនវិលត្រឡប់មកវិញទេ ហើយពួកយើងនឹងបែកគ្នារហូត ។

ក្រោយមក កម្មាភិបាលខ្មែរក្រហមបានមកកាន់ផ្ទះរបស់អ្នកស្រី ដើម្បីសួរនាំពីប្ដីរបស់អ្នកស្រី ។ នៅក្នុងពេលជួបនោះ បងថ្លៃស្រីរបស់អ្នកស្រីបានចោទប្ដីរបស់អ្នកស្រីថា សេ.អ៊ី.អា ។ អ្នកស្រី ឈិន ណាវី មិនយល់ទាល់តែសោះថា តើហេតុអ្វីបានជាបងថ្លៃស្រីខ្លួនឯងអាចក្បត់គ្រួសារ ដោយការកុហកបែបនេះទៅវិញ ហើយអ្នកស្រីស្រក់ទឹកភ្នែកយំ ខណៈពេលដែលរៀបរាប់ឡើងវិញនូវហេតុការណ៍មួយនេះ ។ ក្រោយមក អ្នកស្រី និងកូនត្រូវបានបញ្ជូនទៅកាន់កន្លែងកសាងខ្លួន ដែលនៅទីនោះជនរងគ្រោះទាំងអស់ត្រូវបានបង្ខំឲ្យធ្វើការ ដោយព្រមានថា ប្រសិនបើមិនធ្វើតាមបញ្ជាឲ្យ អ្នកទាំងនោះនឹងមិនរស់ទេ ។

ក្រោយពីថ្ងៃរំដោះបានទីក្រុងភ្នំពេញ អ្នកស្រី ជីន ណាវី បានវិលត្រឡប់មកកាន់ទីក្រុងវិញ ដោយសង្ឃឹមថានឹងបានជួបជុំជាមួយប្ដីរបស់អ្នកស្រីម្ដងទៀត ។ អ្នកស្រីមិនទទួលដំណឹងទាក់ទងនឹងប្ដីរបស់អ្នកស្រីរហូតមកដល់ឆ្នាំ១៩៨០ នៅពេលដែលអ្នកស្រីបានមកមើលមន្ទីរស-២១ ។ នៅពេលដែលទៅដល់ទីនោះ អ្នកស្រីបានឃើញបន្ទប់ឃុំឃាំងតូចៗជាច្រើន និងត្រូវបានប្រាប់ពីរឿងរ៉ាវគួរឲ្យព្រឺខ្លាចដែលបានកើត

ឡើងនៅក្នុងគុក ។ អ្នកស្រីបានសន្លប់បាត់ស្មារតី នៅពេលដែលអ្នកស្រីបានប្រទះឃើញរូបថតប្តីរបស់អ្នកស្រី និងឯកសារដែលបង្ហាញប្រាប់ថា ប្តីរបស់អ្នកស្រីត្រូវបានចាប់ខ្លួន និង «កម្ទេច» នៅមន្ទីរ ស-២១ ។ អ្នកស្រីនៅតែមិនហ៊ានវិលត្រឡប់ទៅមើលគុកទួលស្លែងម្តងទៀតឡើយ ។ អ្នកស្រីបានព្យាយាមធ្វើជារឹងមាំដើម្បីកូនៗរបស់ខ្លួន ប៉ុន្តែការចិញ្ចឹមបីបាច់កូនៗដោយគ្មានឪពុកបែបនេះ គឺជាការលំបាកខ្លាំងណាស់ ។ អ្នកស្រីបានរៀបរាប់ថា គ្មានអ្វីដែលអាចព្យាបាលការឈឺចាប់របស់អ្នកស្រីបានទេ ពីព្រោះអ្នកស្រីមិនអាចគេចចេញពីរូបភាពប្តីរបស់អ្នកស្រីដែលត្រូវបានធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរ ស-២១ នោះឡើយ ។ ក្រោយស្តាប់សក្ខីកម្មដ៏វែង និងរំជួលចិត្តនេះមក លោកប្រធានចៅក្រមជំនុំជម្រះបានមានប្រសាសន៍ថ្លែងអំណរគុណដល់អ្នកស្រី និងបានធ្វើចំណាប់អារម្មណ៍ថា អង្គជំនុំជម្រះបានស្តាប់នូវសក្ខីកម្មគ្រប់គ្រាន់ ។

ដើមបណ្តឹងរដ្ឋប្បវេណី តួច មុន្និន បានបង្ហាញខ្លួននៅក្នុងពេលរសៀលបន្តិចទៅហើយ ។ គាត់បានចាប់ផ្តើមរៀបរាប់ជាលម្អិតនូវព្រឹត្តិការណ៍ ដែលកើតឡើងក្នុងការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ។ សក្ខីកម្មរបស់គាត់មិនបានប៉ុន្មាននាទីផង មេធាវីការពារក្តីបានជំទាស់ដោយធ្វើការកត់សម្គាល់ថា បើទោះបីជាហេតុការណ៍ដែលទាក់ទិននឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ មានសារសំខាន់ជាប្រវត្តិសាស្ត្រក៏ដោយ ហេតុការណ៍ទាំងនោះគឺស្ថិតនៅក្រៅព្រំដែននៃសក្ខីកម្មរបស់លោក តួច មុន្និន ។ អង្គជំនុំជម្រះបានយល់ស្របតាមការជំទាស់របស់មេធាវីការពារក្តី ហើយក្រើនរំឭកដល់សេចក្តីណែនាំរបស់ខ្លួនកាលពីលើកមុនថា សូមដើមបណ្តឹងរដ្ឋប្បវេណីផ្តោតតែលើហេតុការណ៍ដែលជាប់ពាក់ព័ន្ធបានហើយ ។ លោក តួច មុន្និន បានបន្តសក្ខីកម្មរបស់ខ្លួន ដោយរៀបរាប់ថា គាត់បានទៅទីនោះដើម្បីទៅលេងផ្ទះរបស់បងជីដូនមួយ និងដើម្បីធ្វើឲ្យការចងចាំរបស់បងជីដូនមួយគាត់នៅឋិតថេរជារៀងរហូត ។ បងជីដូនមួយរបស់គាត់ទទួលបានបរិញ្ញាប័ត្រផ្នែកវិស័យកម្មនៅប្រទេស រូស្ស៊ី និងរស់នៅស្រុកក្រៅ ខណៈពេលដែលទីក្រុងភ្នំពេញបានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ប៉ុន្តែបីខែក្រោយមក បងជីដូនមួយរបស់គាត់ក៏បានវិលត្រឡប់មកស្រុកខ្មែរវិញ ។ ដូចអ្នកបេះដឹងដទៃទៀតដែរ បងជីដូនមួយរបស់លោក តួច មុន្និន ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ ដែលចុងបញ្ចប់ត្រូវបានសម្លាប់ចោលនៅទីនោះតែម្តង ។